002/19-09-2007-ECCC/TC
E1/153

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 08 / 01 / 2013
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសង

## ថ្ងៃ ព្រហស្បតិ៍ ទី ១៣ ខែ ធ្នូ ឆ្នាំ ២០១២

## សវនាការលើអង្គសេចក្តី- ថ្ងៃទី ១៤០

រៀបចំដោយ: ដាវ អានសាន និង Matteo CRIPPA

| **កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ** |
|---|
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធួ មណី, ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោក ដាវ អានសាន, លោក Matteo CRIPPA, លោកស្រី សែ គុលវុឌ្ឍី |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក ចាន់ ដារារស្មី, លោក Vincent DE WILDE D'ESTMAEL |
| ជនជាប់ចោទ៖ នួន ជា, ខៀវ សំផន, អៀង សារី (ពីបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ) |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Andrew IANUZZI, លោក Jasper PAUW |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម, លោក Michael KARNAVAS |

| |
|---|
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោក Arthur VERCKEN |
| មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖ លោកស្រី Elisabeth SIMONNEAU-FORT, លោក ពេជ អង្គ, លោក សំ សុគង់, លោក ហុង គីមសួន, លោកស្រី Christine MARTINEAU, លោកស្រី Isabelle DURAND, លោក ឡៅ ជុនធី, លោក Mr. Emmanuel JACOMY, លោក វ៉េន ពៅ |
| សាក្សី៖ លោក ខាំ ផាន់ ហៅ ផាន វ៉ាន (TCW-307) (លោក ម៉ម ឫទ្ធា ជាមេធាវីអម)<br>ដើមបណ្ដឹងរដ្ឋប្បវេណី៖ AFFONCO Denise (TCCP-01) ដែលមានវត្តមានមេធាវីអម Julien RIVET |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ, លោកស្រី សួ សុទ្ធាវី |
| ផ្សេងៗ៖ កញ្ញា Sonia MESSAOUDI |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១២ | ចាប់ផ្ដើមម៉ោង៖ ០៩.០៥ | បញ្ចប់ម៉ោង៖ ១៦.៣៥ |
| សម្រាកពេលព្រឹក | ចាប់ផ្ដើមម៉ោង៖ ១០.៣០ | បញ្ចប់ម៉ោង៖ ១០.៥០ |
| សម្រាកពេលថ្ងៃត្រង់ | ចាប់ផ្ដើមម៉ោង៖ ១២.១០ | បញ្ចប់ម៉ោង៖ ១៤.០០ |
| សម្រាកពេលល្ងាច | ចាប់ផ្ដើមម៉ោង៖ ១៥.៣០ | បញ្ចប់ម៉ោង៖ ១៥.៤៥ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ ០៥ ម៉ោង និង ០៥ នាទី | |

**កិច្ចដំណើរការនីតិវិធី៖**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្ដើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការបន្តស្ដាប់សក្ខីកម្មរបស់សាក្សី ផាន វ៉ាន ហៅ ខាំ ផាន់ (TCW-307) | អង្គជំនុំជម្រះ | ០៩.០៧ | ០៩.៣៥ |
| | មេធាវី នួន ជា | ០៩.៣៥ | ១២.០៤ |
| | | ១៥.៤៧ | ១៦.២១ |
| | មេធាវី ខៀវ សំផន | ១៦.២២ | ១៦.៣១ |
| សេចក្ដីសម្រេចលើការប្រព្រឹត្តរបស់មេធាវីការពារក្ដី Andrew IANUZZI | អង្គជំនុំជម្រះ | ១១.៤៨ | ១១.៥២ |
| ការស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ | ជនជាប់ចោទ នួន ជា | ១២.០៦ | ១២.០៨ |
| ការស្នើសុំរបស់ក្រុមការពារក្ដី អៀង សារី | មេធាវី អៀង សារី | ១២.០៤ | ១២.០៤ |

| | | | |
|---|---|---|---|
| ផ្អាកសវនាការរហូតមានការពិនិត្យស្ថានភាពសុខភាពរបស់ អៀង សារី | | | |
| ការបន្តស្តាប់សក្ខីកម្ម និងការថ្លែងអំពីទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណី AFFONCO Denise (TCCP-01) | មេធាវី នួន ជា<br>មេធាវី អៀង សារី<br>មេធាវី ខៀវ សំផន<br>ដើមបណ្តឹងរដ្ឋប្បវេណី | ១៤.០៧<br>១៥.១៧<br>១៥.១៨<br>១៥.១៩ | ១៥.១៦<br>១៥.១៨<br>១៥.១៨<br>១៥.២៦ |
| សេចក្តីថ្លែងរបស់មេធាវី Jasper PAUW ចំពោះថ្ងៃចុងក្រោយរបស់គាត់នៅ អវតក | មេធាវី នួន ជា | ១៦.៣២ | ១៦.៣៣ |

**សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការបន្តស្តាប់សក្ខីកម្មរបស់សាក្សី ផាន វ៉ាន ហៅ ខាំ ផាន់ (TCW-307)**

អង្គជំនុំជម្រះ បានបន្តសាកសួរដល់សាក្សី និងជាបន្ទាប់ ក្រុមការពារក្តី នួន ជា បានតាំងសំណួរដល់សាក្សីសម្រាប់វេលានៅសល់នាពេលព្រឹក និងបានបន្តសំណួរនៅវគ្គទី២ បន្ទាប់ពីការសម្រាកនៅវេលារសៀល។ មេធាវី ខៀវ សំផន បានបន្តការតាំងសំណួរបន្ទាប់ពីក្រុមមេធាវី នួន ជា។

**សេចក្តីសម្រេចលើការប្រព្រឹត្តរបស់មេធាវីអន្តរជាតិការពារក្តី នួន ជា នៅក្នុងសវនាការ**

អង្គជំនុំជម្រះបានសម្រេចលើការប្រព្រឹត្តរបស់មេធាវីអន្តរជាតិការពារក្តី នួន ជា លោក Andrew Ianuzzi នៅក្នុងសាលសវនាការ។ អង្គជំនុំជម្រះយល់ឃើញថា ការប្រព្រឹត្តរបស់មេធាវីរូបនេះជាការប្រមាថមើលងាយ រាំងស្ទះដល់កិច្ចដំណើរការនីតិវិធី និងដោយអនុវត្តតាមវិធាន ៣៨ (១) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះបានសម្រេចបណ្តេញមេធាវីរូបនេះចាកចេញពីបន្ទប់សវនាការសម្រាប់រយៈពេល១ថ្ងៃ។

**ការស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់**

ជនជាប់ចោទ នួនជា តាមរយៈមេធាវីរបស់គាត់ បានស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់សម្រាប់ពេលរសៀល។ អង្គជំនុំជម្រះយល់ព្រមតាមការស្នើសុំ ។

**ការស្នើសុំរបស់ក្រុមការពារក្តី អៀង សារី ផ្អាកសវនាការរហូតមានការពិនិត្យស្ថានភាពសុខភាពរបស់ អៀង សារី**

ក្រុមការពារក្តី អៀង សារី បានទទួលរបាយការណ៍ពីអ្នកគ្រប់គ្រងសំណុំរឿងរបស់ខ្លួន ថា អៀង សារី

មិនបានតាមដានសវនាការចាប់ពីម៉ោង ១១.៤៩នាទី ហើយចង្វាក់បេះដូងរបស់គាត់មានភាពមិនប្រក្រតី។ ដូច្នេះ ក្រុមមេធាវី អៀង សារី ស្នើសុំអង្គជំនុំជម្រះផ្អាកសវនាការរហូតមានការតាមដានស្ថានភាពសុខភាព របស់ ជនជាប់ចោទ អៀង សារី។ បន្ទាប់ពីទទួលបានរបាយការណ៍ពីវេជ្ជបណ្ឌិតប្រចាំការ សវនាការបន្តជាធម្មតានៅវេលារសៀល។

**<u>ការបន្តស្តាប់សក្ខីកម្ម និងការថ្លែងអំពីទុក្ខសោក</u> <u>របស់ដើមបណ្តឹងរដ្ឋប្បវេណី AFFONCO Denise (TCCP-1)</u> (តាមរយៈសោតទស្សន៍)**

មេធាវីអន្តរជាតិការពារក្តី នួន ជា បានតាំងសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី ដែលផ្តល់សក្ខីកម្មតាមរយៈ សោតទស្សន៍ពីប្រទេសបារាំង នាវេលារសៀល បន្ទាប់ពីការសម្រាកថ្ងៃត្រង់។ មិនមានមេធាវីក្រុមផ្សេងទៀត តាំងសំណួរដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះឡើយ។ ជាបន្ត ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានផ្តល់ឱកាសឲ្យ ថ្លែងទុក្ខសោក។

**<u>សេចក្តីថ្លែងរបស់មេធាវី Jasper PAUW ចំពោះថ្ងៃចុងក្រោយរបស់គាត់នៅ អវតក</u>**

មេធាវីការពារក្តី នួន ជា លោក Jasper PAUW បានប្រាប់ដល់អង្គជំនុំជម្រះថា ថ្ងៃនេះគឺជាថ្ងៃចុងក្រោយ របស់ខ្លួននៅក្នុងសវនាការរបស់ អវតក។

**<u>កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង</u>**

| លេខ E3 | លេខ កសចស | ERN | ចំណងជើង | ចំណាត់ថ្នាក់ | សម្គាល់ជាភាសាខ្មែរ | សម្គាល់ជាភាសាអង់គ្លេស | សម្គាល់ជាភាសាបារាំង |
|---|---|---|---|---|---|---|---|
| E3/1101 | D248/5.1.11 | 00376671<br>00524192<br>00532706 | Telegram on September 23, 1976 : To show opinion to 290 | P | | | |
| E3/1196 | D366/7.1.786 | 00000879<br>00506647<br>00597060 | ជូន ម. ៨៧០ ជាទីស្នេហា និងរលឹក | P | | | |
| E3/877 | 21.17 | 00021513<br>00185226<br>00283109 | ទូរលេខលេខ ៥៤ ជូនម.៨៧០ ជាទីគោរពស្នេហានឹករលឹក: មុខព្រួញ ដាក់ដាំកំទិចយួនស្លាប់ ម្នាក់នៅថ្ងៃទី ២៥-០៥-១៩៧៧ | P | | | |
| E3/1030 | D108/28.76 | 00033312<br>00324806<br>00623150 | ទូរលេខ ០៣ របស់ស.ម សុភា រាយការណ៍ជូនបង ឆាន អំពីសភាពការណ៍ពួក ៧ | P | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| E3/57 | D200/4 | 00287700-00287709<br>00290503-00290511<br>00353098-00353108 | កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី KHAM Phăn ខាំ ផាន់ | P | 00287705 | 00290509 | 00353104 |
| E3/1664 | D222/1.19 | 00742838-00742889<br>00397566-00397749<br>00707390-00707411 | ជីវិតក្នុងតំបន់រំដោះខេត្តមណ្ឌលគីរី | P | | 00397653-54 | |
| E3/58 | D125/160 | 00239934-00239940<br>00250086-00250092<br>00283912-00283918 | កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផាន វ៉ាន់ PHAN Van, Alias KHĂM Phăn | P | 00239937 | 00250089 | 00283915 |
| E3/3977R | D125/160R | TR00273774 (KH) | Audio Recording of the interview of PHAN Van, Alias KHAM Phan | P | | | |
| E3/447 | D369/4 | 00483241-00483252<br>00486520<br>00490547-00490558 | កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី PHAN Van ផាន វ៉ាន | P | | 00486512 | |
| N/A | E9/32.2.29 | 00678309-00678441 | Livre écrit par la partie civile AFFONCO Denise sur les événements qu'elle à vécus pendant les années khmers rouge | P | | | 00678322-24,<br>00678330,<br>00678383,<br>00678385,<br>00678421 |
| E3/3976 | D199/15 | 00349104-00349122<br>00346929-00346937<br>00342178-00342185 | កំណត់ហេតុនៃការស្តាប់ចម្លើយ AFFONCO Denise | P | | 00346936 | |
| E3/2144 | C22/I/32.34 | 00190136-00190706 | Table of Authorities 36: Genocide in Cambodia – Documents from the Trial of P01 Pot and leng Sary, University of Pennsylvania Press, Philadelphia, 2000 | P | | 00190592,<br>00190698 | |
| E3/1195 | D366/7.1.785 | 00057296<br>00519519<br>00531088 | ជូនមិត្ត Pang ជាទីស្រលាញ់និងនឹករលឹក | P | | | |
| E3/1194 | D366/7.1.781 | 00021533<br>00548893<br>00532707 | ទូរលេខ ១០ ជូនបង អំពីការបង្កបង្កើនផលស្រូវ | P | | | |
| E3/1189 | D366/7.1.668 | 00021531<br>00590301<br>00532776 | ទូរលេខ៣ៈ ជូនបងទី១ និងទី២ ពីឡាំង | P | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| E3/1 193 | D366/7.1 .780 | 00021532 00590302 00531061 | ជូនមិត្ត ឡៀន ជាទីស្នេហានិងរលឹក | P | | | | |
| E3/1 192 | D366/7.1 .779 | 00021529 00508560 00499961 | ទូរលេខ ២ ជូនបង នួន | P | | | | |
| E3/1 191 | D366/7.1 .778 | 00021530 00539058 00531062 | ជូនមិត្ត ឡៀន ជាទីស្នេហានិងរលឹក | P | | | | |

**ដីកា/សេចក្ដីសម្រេចផ្ទាល់មាត់៖**

- អង្គជំនុំជម្រះសម្រេចបណ្ដេញមេធាវីការពារក្ដីអន្តរជាតិ នួន ជា លោក Andrew Ianuzzi ចេញពីបន្ទប់សវនាការ សម្រាប់រយៈពេល១ថ្ងៃ ដោយអនុវត្តតាមវិធាន ៣៨(១) នៃវិធានផ្ទៃក្នុង។ បង្គាប់ឱ្យកម្លាំងសន្តិសុខក្នុងសាលសវនាការនាំខ្លួនមេធាវីរូបនេះចេញពីបន្ទប់សវនាការ (ម៉ោង ១១.៥១)។
- អង្គជំនុំជម្រះសម្រេចអនុញ្ញាតិឱ្យជនជាប់ចោទ នួន ជា ចូលរួមដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ និងបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ទៅបន្ទប់ឃុំខ្លួន។
- បង្គាប់ឱ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញជូន សាក្សី ផាន វ៉ាន ហៅ ខាំ ផាន់ (TCW-307) ត្រឡប់ទៅកាន់ទីកន្លែងស្នាក់នៅរបស់គាត់ និងបង្គាប់ឱ្យនាំសាក្សី ផាន វ៉ាន និងមេធាវីរបស់គាត់ ត្រឡប់មកកាន់សាលសវនាការវិញនៅព្រឹកថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២។
- បង្គាប់ឱ្យដើមបណ្ដឹងរដ្ឋប្បវេណី AFFONCO Denise (TCCP-01) ត្រឡប់ទៅគេហដ្ឋានវិញ ដោយសារការផ្ដល់សក្ខីកម្មរបស់គាត់បានចប់ជាស្ថាពរ។
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា ខៀវ សំផន និង អៀង សារី ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំគាត់មកកាន់បន្ទប់សវនាការនៅថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២ (ចំពោះជនជាប់ចោទ អៀង សារី ត្រូវនាំមកកាន់បន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ) ។

**កាលបរិច្ឆេទបន្តសវនាការ៖**

សវនាការនឹងបន្តនៅថ្ងៃ សុក្រ ទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២ វេលាម៉ោង ០៩.00 ព្រឹក។

ភ្នំពេញ ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១២

ក្រឡាបញ្ជី [illegible] ក្រឡាបញ្ជី

ដាវ [illegible] Marco CRIPPA